CHILD CARE SUBSIDY PROGRAMS (CCSP)

# លិខិតផ្តល់សិទ្ធិ **CCSP**

## CCSP Authorization Letter

| ទាក់ទងទៅលេខទូរស័ព្ទមជ្ឈមណ្ឌលទំនាក់ទំនង | ទាក់ទងទៅលេខទូរសារមជ្ឈមណ្ឌលទំនាក់ទំនង |
|---|---|
| លេខសម្គាល់អតិថិជន | កាលបរិច្ឆេទ |

☐ ការថែទាំកុមារតាមរដូវកាល

☐ ការតភ្ជាប់ការងារការថែទាំកុមារ

ការផ្តល់សិទ្ធិថែទាំកុមាររបស់អ្នកត្រូវបានផ្អែកលើព័ត៌មានដែលអ្នកបានផ្តល់ទៅឱ្យ **DSHS**។

ការថែទាំកុមារកំពុងត្រូវបានផ្តល់សិទ្ធិសម្រាប់ សម្រាប់ ☐ កន្លះថ្ងៃ ☐ ពេញមួយថ្ងៃ ☐ ម៉ោង

ការថែទាំកុមារកំពុងត្រូវបានផ្តល់សិទ្ធិសម្រាប់ សម្រាប់ ☐ កន្លះថ្ងៃ ☐ ពេញមួយថ្ងៃ ☐ ម៉ោង

ការថែទាំកុមារកំពុងត្រូវបានផ្តល់សិទ្ធិសម្រាប់ សម្រាប់ ☐ កន្លះថ្ងៃ ☐ ពេញមួយថ្ងៃ ☐ ម៉ោង

ការថែទាំកុមារកំពុងត្រូវបានផ្តល់សិទ្ធិសម្រាប់ សម្រាប់ ☐ កន្លះថ្ងៃ ☐ ពេញមួយថ្ងៃ ☐ ម៉ោង

### <u>សហបង់ប្រាក់</u>

សហបង់ប្រាក់គឺជាចំណែករបស់អ្នកលើការចំណាយការថែទាំកូនរបស់អ្នក និងត្រូវតែត្រូវបានបង់ប្រាក់ដោយផ្ទាល់ទៅអ្នកផ្តល់សេវាកម្មរបស់អ្នក ។ ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យបង់ចំនួនគឺផ្អែកលើទំហំគ្រួសាររបស់អ្នក និងប្រាក់ចំណូលប្រចាំខែរបស់អ្នក ។

☐ សហបង់ប្រាក់ប្រចាំខែរបស់អ្នកនឹងត្រូវជា $ ពី ដល់ ។

☐ សហបង់ប្រាក់ប្រចាំខែរបស់អ្នកនឹងត្រូវជា $ ពី ដល់ ។

ប្រសិនបើអ្នកត្រូវបានតម្រូវឲ្យបង់សហបង់ប្រាក់ អ្នកត្រូវតែបង់វាសម្រាប់ខែណាមួយដែល **DSHS** បង់ប្រាក់សម្រាប់សេវាកម្មថែទាំកុមារ ។ ការបរាជ័យក្នុងការបង់សហបង់ប្រាក់ដែលតម្រូវឱ្យមានរបស់អ្នកអាចបណ្តាលឱ្យមានការលុបចោលមុនពេលនូវអត្ថប្រយោជន៍ការថែទាំកូនរបស់អ្នក **WAC 110-15-0030 & 110-15-0110**។

ព័ត៌មានបន្ថែម ៖

DSHS ចាត់ទុកកុមារថាដល់អាយុចូលរៀន បើពួកគេមានអាយុប្រាំឆ្នាំ ដល់ 12 ឆ្នាំ ត្រឹមថ្ងៃទី 1 ខែកញ្ញា។ បើកូនរបស់អ្នកមានអាយុប្រាំឆ្នាំ តែមិនបានចូលរៀននារដូវស្លឹកឈើជ្រុះនេះទេ សូមទាក់ទងទៅលេខខាងលើ។

<u>ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវាថែទាំកុមារដែលមានអាជ្ញាប័ណ្ណ</u>

ការអនុញ្ញាតពេញមួយថ្ងៃសម្រាប់កុមារគ្រប់អាយុចូលរៀនគឺត្រូវកាត់បន្ថយពាក់កណ្តាលថ្ងៃដោយស្វ័យប្រវត្តិសម្រាប់ឆ្នាំសិក្សា ខែកញ្ញា ដល់ខែឧសភា។

ការអនុញ្ញាតសម្រាប់កុមារគ្រប់អាយុចូលរៀនពេញម៉ោងគឺត្រូវកាត់បន្ថយពាក់កណ្តាលថ្ងៃដោយស្វ័យប្រវត្តិពី 30 ទៅ 46 ពាក់កណ្តាលថ្ងៃសម្រាប់ខែមិថុនា ខែកក្កដា និងខែសីហាដើម្បីឈប់សម្រាករដូវក្តៅ។

ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវាដែលលើកលែងអាជ្ញាប័ណ្ណ ជាគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង

ការអនុញ្ញាតច្រើនជាង 115 ម៉ោងក្នុងមួយខែសម្រាប់កុមារចូលរៀនគឺត្រូវបានកាត់បន្ថយ 115 ម៉ោងសម្រាប់ឆ្នាំសិក្សា ខែកញ្ញា ដល់ខែឧសភា។

ម៉ោង "ការថែទាំថ្ងៃឈប់សម្រាកពីសាលារៀន" ចន្លោះ 35 – 70 ម៉ោងរាល់ខែ អាចរកបានសម្រាប់អ្នកផ្តល់សេវាដើម្បីទាមទារយកអំឡុងពេលឆ្នាំសិក្សា។ ម៉ោងទាំងនេះគ្របដណ្តប់ពេលវេលា នៅពេលកុមារគ្រប់អាយុចូលរៀនគឺមិននៅក្នុងសាលារៀន ដូចជាការចេញមុន និងថ្ងៃមិនរៀន។ អំឡុងពេលឈប់សម្រាករដូវក្តៅ ខែមិថុនា ខែកក្កដា និងខែសីហា មានម៉ោង "ការថែទាំថ្ងៃសម្រាកពីការសិក្សា" ដល់ទៅ 115 ម៉ោងរាល់ខែ។ មានប្រអប់មួយនៅលើវិក្កយបត្រដែលសរសេរថា "ការថែទាំថ្ងៃឈប់សម្រាកពីសាលារៀន" ដែលអ្នកផ្តល់សេវាទាមទារយកម៉ោងបន្ថែមទាំងនេះ។

នឹងផ្លាស់ប្តូរអ្នកផ្តល់សេវា?

ប្រសិនបើអ្នកចង់ផ្លាស់ប្តូរអ្នកផ្តល់សេវាសម្រាប់ហេតុផលណាមួយ ឬមានការផ្លាស់ប្តូរលើតម្រូវការថែទាំរបស់អ្នក អ្នកត្រូវតែទាក់ទង DSHS ក្នុងពេលប្រាំថ្ងៃនៃការផ្លាស់ប្តូរ ដូចដែលបានតម្រូវដោយ WAC 110-15-0031។

ការយល់ដឹងពីការថែទាំកុមារ (Child Care Aware) ផ្តល់ជូនព័ត៌មានឥតគិតថ្លៃ មិនលំអៀង និងសេចក្តីយោងសម្រាប់ក្រុមគ្រួសារដែលស្វែងរកការថែទាំមានគុណភាពខ្ពស់ដែលមានអាជ្ញាប័ណ្ណ។ ទូរស័ព្ទទៅលេខ 1-800-446-1114 ឬលើបណ្តាញនៅ http://wa.childcareaware.org។

ដើម្បីស្វែងរកស្ថានភាពត្រួតពិនិត្យសារពើថែទាំកុមារដែលមានអាជ្ញាប័ណ្ណ ប្រវត្តិចេញអាជ្ញាប័ណ្ណ របាយការណ៍តាមដាន ភាសាដែលបាននិយាយ និងច្រើនទៀត ចូលទៅកាន់ ៖ ការយល់ដឹងពីការថែទាំកុមារ **(Child Care Aware)** នៅ **www.del.wa.gov/check**។

ដើម្បីស្វែងរកព័ត៌មានអំពីព្រឹត្តិការណ៍សំខាន់ខាងការលូតលាស់របស់កុមារ និងលទ្ធភាពរកបាននៃការតាមដានខាងការលូតលាស់ ទូរស័ព្ទទៅខ្សែបណ្តាញទាន់ហេតុការណ៍សុខភាពគ្រួសារ តាមលេខ 1-800-322-2588 ឬចូលទៅកាន់ http://www.parenthelp123.org/child-development/child-development-screening-public

រាយការណ៍ពីកង្វល់ទាំងឡាយអំពីការរំលោភបំពានអាជ្ញាប័ណ្ណដែលអាចទៅរួច ឬការប្រើបំពាន ឬការមិនអើពើលើកុមារ នៅមណ្ឌលថែទាំកុមារ ដោយទូរស័ព្ទទៅលេខ **1-866-End Harm (1-866-363-4276)**។

សិទ្ធិស្នើសុំសវនាការ

បើអ្នកមិនយល់ស្របជាមួយការសម្រេចនេះ អ្នកអាចស្នើសុំសវនាការដោយទាក់ទងការិយាល័យនេះ ឬសរសេរទៅការិយាល័យសវនាការរដ្ឋបាល Office of Administrative Hearings, P.O. Box 42489, Olympia, WA 98504-2489 ។ អ្នកត្រូវតែស្នើសុំសវនាការរបស់អ្នក ៖

- នៅ ឬមុនថ្ងៃមានសុពលភាពនៃចំណាត់ការនេះ ឬមិនលើសពី 10 ថ្ងៃក្រោយពីពួកយើងផ្ញើឲ្យអ្នកនូវសេចក្តីជូនដំណឹងពីចំណាត់ការនេះ បើអ្នកទទួលបានផលប្រយោជន៍ឥឡូវនេះ ហើយអ្នកចង់ឲ្យវានៅតែបន្ត ឬ
- ក្នុងរយៈពេល 90 ថ្ងៃពីកាលបរិច្ឆេទដែលអ្នកទទួលបានលិខិតនេះ ។

នៅសវនាការ អ្នកមានសិទ្ធិតំណាងខ្លួនឯង ត្រូវបានតំណាងដោយមេធាវី ឬដោយបុគ្គលផ្សេងទៀតដែលអ្នកជ្រើសរើស ។ អ្នកអាចទទួលបានយោបល់ផ្នែកច្បាប់ ឬការតំណាងដោយឥតគិតថ្លៃ ដោយទាក់ទងការិយាល័យសេវាកម្មច្បាប់ ។

ការរាយការណ៍ពីការផ្លាស់ប្តូរទូរស័ព្ទ

ទូរស័ព្ទ 1-877-501-2233 ឬទូរសារ 1-888-338-7410

លើបណ្តាញនៅ ៖ https://www.washingtonconnection.org/home/

សំបុត្រ ៖ DSHS Customer Service Contact Center
P.O. Box 11699
Tacoma WA 98411
បញ្ចូលលេខសម្គាល់អតិថិជនរបស់អ្នកលើទំព័រនីមួយៗដែលអ្នកបញ្ជូនមក ។